00938044

E287/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣

សាធារណៈ / Public

**ជូនចំពោះ:** ក្រុមវេជ្ជបណ្ឌិតព្យាបាលលោក នួន ជា

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** ចៅក្រមទាំងអស់ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ការិយាល័យរដ្ឋបាល គ្រប់ភាគីទាំងអស់នៃរឿងក្តី

**កម្មវត្ថុ:** កាលវិភាគស្តាប់សក្ខីកម្មជនជាប់ចោទ នួន ជា

ជនជនចោទ នួន ជា បានបង្ហាញចេតនាឆ្លើយតបទៅនឹងសំណួរដែលចោទសួរដោយភាគី និងអង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E 287)។ ក៏ប៉ុន្តែ ជនជាប់ចោទក៏បានបញ្ជាក់ផងដែរថា "ដោយសារលោកនៅបន្តមានអាការៈល្ហិតល្ហៃ លទ្ធភាពរបស់លោកនៅក្នុងការឆ្លើយតបទៅនឹងសំណួរក្នុងពេលយូរណាមួយ អាចមានកម្រិតតិចតួច"។ ក្រោយពីបានពិចារណាយ៉ាងល្អិតល្អន់លើសុខភាពទ្រុឌទ្រោមរបស់ជនជាប់ចោទ អង្គជំនុំជម្រះបានសម្រេចស្តាប់សក្ខីកម្មជនជាប់ចោទនៅក្នុងវគ្គសវនាការតែពេលព្រឹកប៉ុណ្ណោះ ដោយអនុវត្តតាមកាលវិភាគដែលបានកំណត់ដូចខាងក្រោម៖

| | |
|---|---|
| ម៉ោង ៩:០០ - ៩:៤៥ ព្រឹក | សវនាការវគ្គទីមួយ |
| ម៉ោង ៩:៤៥ - ១០:០០ ព្រឹក | សម្រាក |
| ម៉ោង ១០:០០ - ១០:៤៥ ព្រឹក | សវនាការវគ្គទីពីរ |
| ម៉ោង ១០:៤៥ - ១១:០០ ព្រឹក | សម្រាក |
| ម៉ោង ១១:០០ - ១១:៣០ ព្រឹក | សវនាការវគ្គទីបី |
| ម៉ោង ១១:៣០ ព្រឹក | ផ្អាកសវនាការ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 07 / 2013
ម៉ោង (Time/Heure) : 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោក នួន ជា ផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ប្រសិនបើគាត់ជ្រើសរើសធ្វើដូច្នេះ។ បើមិនដូច្នោះទេ លោក នួន ជា នឹងផ្តល់សក្ខីកម្មពីបន្ទប់ឃុំខ្លួនដែលស្ថិតនៅពីខាងក្រោម

សាលសវនាការ។ ជាការពិត អង្គជំនុំជម្រះនឹងពិចារណាលើគ្រប់កត្តាពាក់ព័ន្ធទាំងអស់នៅពេលសម្រេចថាតើត្រូវអនុវត្តតាមកាលវិភាគនេះជារៀងរាល់ថ្ងៃដដែល ឬក៏យ៉ាងណា។

តាមការដឹងអំពីស្ថានភាពសុខភាពបច្ចុប្បន្នរបស់ជនជាប់ចោទ នួន ជា សូមលោក/លោកស្រី វេជ្ជបណ្ឌិតធ្វើរបាយការណ៍ជូនមកអង្គជំនុំជម្រះឲ្យបានត្រឹមថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ ដោយបញ្ជាក់ថាតើកាលវិភាគខាងលើសមស្របតាមលក្ខណៈវេជ្ជសាស្ត្រដែរ ឬទេ។ ជនជាប់ចោទអាចនឹងចាប់ផ្តើមផ្តល់សក្ខីកម្ម យ៉ាងលឿនបំផុតនោះ គឺនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ ។